មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# កំណត់ត្រាសង្ខេប
# ខែវិច្ឆិកា ឆ្នាំ២០១៤
# និទណ្ឌភាពក្នុងប្រទេសកម្ពុជា

## តើនិទណ្ឌភាពជាអ្វី?

និទណ្ឌភាព មានន័យថា "ការមិនត្រូវបានផ្តន្ទាទោស" ឬ "គ្មានផលវិបាកណាមួយ"។ ជនប្រព្រឹត្តបទល្មើសតែងតែមិនត្រូវបានផ្តន្ទាទោសចំពោះអំពើដែលខ្លួនប្រព្រឹត្ត ហើយជនរងគ្រោះមិនដែលទទួលបានភាពយុត្តិធម៌នោះទេ។ ដោយសារតែ កង្វះឆន្ទៈក្នុងការផ្តន្ទាទោសទៅលើជនប្រព្រឹត្តបទល្មើសទាំងនោះ បានធ្វើឲ្យបទល្មើសទាំងនោះតែងតែមិនត្រូវបានស៊ើបអង្កេតឲ្យត្រឹមត្រូវ និងឯករាជ្យ ឬសំណងសមរម្យសម្រាប់ជនរងគ្រោះ។ វប្បធម៌និទណ្ឌភាពបានគំរាមកំហែងលើសិទ្ធិទទួលបានការពិត[1] យុត្តិធម៌ និងសំណងត្រឹមត្រូវ[2] ហើយបង្កឲ្យមានភាពភ័យខ្លាចក្នុងការអនុវត្តសិទ្ធិសេរីភាពនៃការបញ្ចេញមតិរបស់បុគ្គល។

អនុលោមតាមតាមគោលការណ៍មួយនៃបណ្តុំគោលការណ៍អង្គការសហប្រជាជាតិ សម្រាប់ការពារ និងលើកកម្ពស់សិទ្ធិមនុស្សតាមរយៈសកម្មភាពប្រយុទ្ធប្រឆាំងនឹងនិទណ្ឌភាពបានចែងថា ៖

*"និទណ្ឌភាពកើតឡើងដោយសារតែការខកខានរបស់រដ្ឋ ក្នុងការអនុវត្តកាតព្វកិច្ចរបស់ខ្លួនដើម្បីស៊ើបអង្កេតចំពោះការរំលោភបំពាន, ចាត់វិធានការសមស្របសម្រាប់ជនល្មើស ជាពិសេសក្នុងបរិបទយុត្តិធម៌ ដោយធានាថាជនសង្ស័យនៃការទទួលខុសត្រូវព្រហ្មទណ្ឌនឹងត្រូវបានចោទប្រកាន់ សម្រេចក្តី និងផ្តន្ទាទោស ដើម្បីផ្តល់សំណងដ៏មានប្រសិទ្ធភាពដល់ជនរងគ្រោះ និងធានាថាពួកគេទទួលសំណងចំពោះការខូតខាតដែលកើតមានចំពោះខ្លួនគេ, ធានានូវសិទ្ធិដែលមិនអាចដកហូតបាននៃការទទួលបានការពិតស្តីពីការរំលោភបំពាន និងចាត់វិធានការចាំបាច់ដទៃទៀត ដើម្បីការពារការកើតឡើងបទល្មើសទាំងនោះម្តងទៀត"។*[3]

កំណត់ត្រាសង្ខេបនេះបង្ហាញអំពីបញ្ហានិទណ្ឌភាពស្ថិតក្នុងទម្រង់ផ្សេងៗ ដែលកើតឡើងនៅកម្ពុជា ដែលមានដូចជា ករណីឃាតកម្មលើសកម្មជនសិទ្ធិមនុស្ស និងអ្នកសារព័ត៌មាន ដែលអំពើទាំងអស់នោះមិនត្រូវ

[1] ឧត្តមស្នងការ អសប ទទួលបន្ទុកសិទ្ធិមនុស្ស «ការសិក្សាលើសិទ្ធិទទួលបានការពិត» (របាយការណ៍) (E/CN.4/2006/91), (ថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០០៦), http://bit.ly/OfPl2f.

[2] មាត្រា ៨ នៃ សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស (ស.ប.ស.ស) និង មាត្រា ២ នៃ កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ក.ស.ព.ស.ន)។

[3] ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម នៃ អសប «ការលើកកម្ពស់ និងការពារសិទ្ធិមនុស្ស ៖ បណ្តុំគោលការណ៍ដែលត្រូវបានបន្ទាន់សម័យ សម្រាប់ការការពារ និងការលើកកម្ពស់សិទ្ធិមនុស្សតាមរយៈសកម្មភាពដើម្បីលុបបំបាត់និទណ្ឌភាព» គណៈកម្មការស្តីពីសិទ្ធិមនុស្ស កិច្ចប្រជុំទី ៦១ ចំណុច ១៧ (ថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០០៥) http://bit.ly/1hHxrQi

បានស៊ើបអង្កេត និងករណីដែលកងកម្លាំងសន្តិសុខបានប្រើប្រាស់អំពើហិង្សាមកលើជនស៊ីវិល និងសកម្មភាពរបស់មន្ត្រីដែលមានទំនាក់ទំនងល្អជាមួយអ្នកកាន់អំណាចក៏មិនត្រូវបានយកមកផ្តន្ទាទោសផងដែរ។

កំណត់ត្រាសង្ខេបនេះតាក់តែងឡើងដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក) ជាអង្គការមិនមែនរដ្ឋាភិបាល មិនមាននិន្នាការនយោបាយ ឯករាជ្យ ដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្សពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅកម្ពុជា។

## និទណ្ឌភាព និងការប្រើប្រាស់អំពើហិង្សាទៅលើអ្នកតវ៉ា

អំពើហិង្សាមកលើក្រុមអ្នកតវ៉ាដែលបានកើតឡើងនាពេលថ្មីៗនេះ និងខកខានក្នុងការនាំយកជនល្មើសទៅផ្តន្ទាទោសជាទម្រង់ដ៏សំខាន់មួយនៃនិទណ្ឌភាពដែលកំពុងកើតឡើងនៅកម្ពុជា។

នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៣ អ្នកគាំទ្រគណបក្សសង្គ្រោះជាតិកម្ពុជា (គ.ស.ជ) យ៉ាងហោចណាស់ចំនួន ២០,០០០ នាក់បានជួបជុំគ្នានៅទីលានប្រជាធិបតេយ្យ ដើម្បីបង្ហាញពីការមិនពេញចិត្តចំពោះលទ្ធផលបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនាខែកក្កដា ឆ្នាំ២០១៣។ ការជួបជុំរបស់ក្រុមអ្នកគាំទ្របានប្រឈមមុខជាមួយនឹងមន្ត្រីនគរបាល និងកងបង្ក្រាបកុប្បកម្ម ដែលមានបំពាក់ដោយ កាំភ្លើង គ្រាប់ជ័រ ឧស្ម័នបង្ហូរទឹកភ្នែក គ្រាប់បែកផ្សែង និងឡានបាញ់ទឹក ហើយការប៉ះទង្គិចគ្នាកើតមានឡើងជុំវិញទីក្រុង។ នាអំឡុងពេលមានអំពើហិង្សានោះ កងកម្លាំងរក្សាសន្តិសុខបានបាញ់គ្រាប់កាំភ្លើងពិតទៅលើក្រុមអ្នកតវ៉ា ដែលបណ្តាលឲ្យលោក ម៉ៅ សុខចាន់ ដែលជាអ្នកឈរមើលម្នាក់ អាយុ ២៩ ឆ្នាំ ស្លាប់ ក្នុងខណៈដែលរូបគាត់មានបំណងធ្វើដំណើរទៅផ្ទះ ព្រមទាំងបណ្តាលមនុស្សយ៉ាងហោចណាស់ ១០នាក់ផ្សេងទៀតរងរបួស។[4]

នៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៣ លោកស្រី អេង សុខុម អាយុ ៤៩ ឆ្នាំ អ្នកលក់ដូរតាមដងផ្លូវ ហើយជាអ្នកឈរមើលដែរនោះ ក៏ត្រូវបាញ់សម្លាប់ក្នុងអំឡុងពេលមានការតវ៉ានៅមុខរោងចក្រ អែស អិល ផងដែរ។ ក្រុមអ្នកតវ៉ាចំនួន ៩ នាក់ ផ្សេងទៀតត្រូវរងរបួសដោយសារការបាញ់ប្រហារពីសំណាក់មន្ត្រីនគរបាល ហើយម្នាក់ក្នុងចំណោមនោះទទួលរងរបួសរហូតធ្លាក់ខ្លួនពិការអចិន្ត្រៃយ៍ ហើយជាអ្នកតវ៉ាជាច្រើននាក់ទៀតត្រូវបានវាយនឹងដំបងយ៉ាងដំណំ។[5]

នៅថ្ងៃទី២ ខែមករា ឆ្នាំ២០១៤ មានការវាយដំ និងឃាត់ខ្លួនព្រះសង្ឃចំនួន ៥អង្គ រួមទាំងសហជីព និងកម្មករកាត់ដេរ នៅមុខរោងចក្រ យ៉ាក ជីង នៅជាយក្រុងភ្នំពេញ។[6] នាព្រឹកថ្ងៃទី៣ ខែមករា ឆ្នាំ២០១៤ មនុស្ស ១៣ នាក់ ផ្សេងទៀតត្រូវបានឃាត់ខ្លួនក្នុងពេលធ្វើការតវ៉ានៅផ្លូវ វេង ស្រេង។ ក្នុងអំឡុងពេលបំបែកការតវ៉ា កងកម្លាំងរក្សាសន្តិសុខបានបាញ់ប្រហារទៅក្រុមអ្នកតវ៉ាទាំងនោះ ដែលបណ្តាលឲ្យ លោក យ៉ាន រិទ្ធី អាយុ ២៥ ឆ្នាំ, លោក ផេង កុសល អាយុ ២២ ឆ្នាំ, លោក គីម ផលលាភ អាយុ ២៥ ឆ្នាំ ស្លាប់ និងមានអ្នករង

---

[4] មាស សុខជា និងសហការី «ការតវ៉ាឈានដល់សភាពខ្មៅងងឹត» ឌឹ ភ្នំពេញ ប៉ុស្តិ៍ (ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៣) http://bit.ly/1qpus5U

[5] ម.ស.ម.ក «ការប្រើប្រាស់កម្លាំងហួសហេតុទៅលើបាតុកម្មរបស់កម្មករ» (សលាកប័ត្រព័ត៌មាន) (ខែវិច្ឆិកា ឆ្នាំ២០១៣) http://bit.ly/1cKfOu4.

[6] ម.ស.ម.ក «ការចាប់ខ្លួន និងចោទប្រកាន់មកលើអ្នកការពារសិទ្ធិមនុស្ស លោក វ៉ន ពៅ ប្រធាន សមាគមប្រជាធិបតេយ្យឯករាជ្យ នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ» (សេចក្តីប្រកាសព័ត៌មានបន្ទាន់) (ថ្ងៃទី៣ ខែមករា ឆ្នាំ២០១៤) http://bit.ly/1dMuwAD.

របួសជាច្រើននាក់ទៀត។[7] បន្ថែមពីលើនោះ យុវជន ខឹម សុផាត អាយុ ១៦ ឆ្នាំ បានបាត់ខ្លួនក្នុងខណៈនោះ។ លិខិតមួយរបស់សង្គមស៊ីវិលជាតិ និងអន្តរជាតិចំនួន ៥៤ រួមទាំង ម.ស.ម.ក ផងដែរ បានបញ្ជាក់ថា មានសាក្សីម្នាក់ឃើញយុវជន ខឹម សុផាត ត្រូវបានបាញ់ចំដងខ្លួន។ ចាប់តាំងពីអំពើហិង្សានោះកើតឡើង អាជ្ញាធរមិនដែលបញ្ចេញព័ត៌មានបង្ហាញពីកន្លែងរស់នៅរបស់យុវជននោះទេ ដែលប្រការនេះនាំឲ្យគេជឿថាជាការបាត់ខ្លួនដោយបង្ខំ។[8]

ការស្លាប់របស់ជនរងគ្រោះខាងលើ បណ្តាលមកពីការប្រើប្រាស់កម្លាំងហួសហេតុពីសំណាក់កងកម្លាំងរក្សាសន្តិសុខ ដែលឈានដល់ការសម្លាប់មនុស្សដោយខុសច្បាប់។ យោងតាមគោលការណ៍ជាមូលដ្ឋានរបស់អង្គការសហប្រជាជាតិស្តីពីការប្រើប្រាស់កម្លាំង និងអាវុធរបស់មន្ត្រីអនុវត្តច្បាប់ ការប្រើប្រាស់កម្លាំងអាចស្របច្បាប់បានលុះណាតែ វិធានការណ៍អហិង្សាត្រូវបានប្រើប្រាស់អស់ពីលទ្ធភាព ហើយត្រូវតែសមស្របនឹងគោលបំណងនៃច្បាប់ផងដែរ។[9] បន្ថែមពីលើនេះ អាវុធអាចប្រើប្រាស់បានសម្រាប់តែការការពារខ្លួន ឬការពារអ្នកដទៃប្រឆាំងនឹងការគំរាមកំហែងដល់អាយុជីវិត ឬការរងរបួសធ្ងន់ធ្ងរប៉ុណ្ណោះ។[10] តាមមូលដ្ឋាននេះ ការប្រើប្រាស់កម្លាំងរបស់កងកម្លាំងរក្សាសន្តិសុខគឺមិនស្របច្បាប់ មិនសមាមាត្រ និងហួសហេតុ។ ការបាញ់សម្លាប់លើក្រុមអ្នកតវ៉ាជាការរំលោភសិទ្ធិរស់រានមានជីវិត និងសិទ្ធិសេរីភាពមានសុវត្ថិភាពផ្ទាល់ខ្លួន[11] ដែលចែងជាសិទ្ធិមូលដ្ឋានក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងត្រូវបានធានាដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

ទោះបីជាយ៉ាងនេះក៏ដោយ ស្ថានភាពនេះបានឈានដល់និទណ្ឌភាព និងមិនមានការការស៊ើបអង្កេតដោយឯករាជ្យ និងត្រឹមត្រូវណាមួយត្រូវបានធ្វើឡើងនោះទេ។ ក្នុងខែមករា ឆ្នាំ២០១៤ គណៈកម្មការស៊ើបអង្កេត ចំនួន ២ ត្រូវបានបង្កើតឡើងដើម្បីពិនិត្យទៅលើស្ថានភាពដែលបានកើតឡើង ព្រមទាំងវាយតម្លៃទៅលើការខូចខាតដែលបង្កឡើងដោយក្រុមអ្នកតវ៉ា។[12] គណៈកម្មការទាំង ២ នោះក៏ទទួលខុសត្រូវលើការកំណត់អត្តសញ្ញាណជនដែលបាញ់ប្រហារទៅលើក្រុមអ្នកតវ៉ាផងដែរ។ ក៏ប៉ុន្តែ ដំណើរការរបស់គណៈកម្មការទាំង ២ នោះ ពុំមានឯករាជ្យភាព និងតម្លាភាពឡើយ ដោយហេតុថារដ្ឋមន្ត្រីក្រសួងមហាផ្ទៃជាប្រធានគណៈកម្មការដែលទទួលបន្ទុកស៊ើបអង្កេតរកជនដែដល់ដែលបានបាញ់ប្រហារទៅលើក្រុមអ្នកតវ៉ា។ មិនតែប៉ុណ្ណោះ លទ្ធផលនៃការស៊ើបអង្កេតរបស់គណៈកម្មការនេះ ក៏មិនត្រូវបានបង្ហាញជាសាធារណៈផងដែរ។

សកម្មភាពរបស់រាជរដ្ឋាភិបាលកម្ពុជា (រដ្ឋាភិបាល) ជាការលម្អៀងទៅខាងកងកម្លាំងរក្សាសន្តិសុខ។ ក្នុងខែមករា ឆ្នាំ២០១៤ មន្ត្រីរដ្ឋាភិបាលចំនួន ៥ នាក់ ដែលមិនបានបង្ហាញអត្តសញ្ញាណត្រូវបានព្រះរាជអាជ្ញាកោះហៅឲ្យមកបំភ្លឺនៅសាលាដំបូងរាជធានីភ្នំពេញ លើករណីជាប់ពាក់ព័ន្ធនឹងការប្រើប្រាស់ហិង្សា។[13] យោង

---

7 លីកាដូ «បញ្ជីឈ្មោះអ្នកស្លាប់ និងបាត់ខ្លួន កាលពីថ្ងៃទី៣ ខែមករា ឆ្នាំ២០១៤» http://bit.ly/1kpFgxK.

8 «លិខិតសាធារណៈជំរុញឲ្យមានការស៊ើបអង្កេត មកលើការបាត់ខ្លួនរបស់ ខឹម សុផាត» http://bit.ly/1nYPp2d.

9 អង្គការសហប្រជាជាតិ គោលការណ៍មូលដ្ឋាន ស្តីពីការប្រើប្រាស់កម្លាំង និងអាវុធរបស់មន្ត្រីអនុវត្តច្បាប់ ថ្ងៃទី២៧ ខែសីហា ឆ្នាំ១៩៩០ បញ្ញត្តិទី ៤ និង ទី ៥ (ក) http://bit.ly/1dtR5f7.

10 ដូចខាងលើ បញ្ញត្តិ ៩

11 មាត្រា ៣ និង ៩ នៃ ស.ប.ស.ស, មាត្រា ៦ និង ៩ (១) នៃ ក.អ.ស.ព.ន

12 ម៉ៃ ទិត្យថារ៉ា «ក្រុមអង្គការសង្គមស៊ីវិលរិះគន់ចំពោះការស៊ើបអង្កេតរបស់រដ្ឋាភិបាល» ឌឹ ភ្នំពេញ ប៉ុស្ដិ៍ (ថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៤)

13 ប៊ុត រស្មីគង្គា និង ដានីញ៉ែល ផាយ «សួរចម្លើយមន្ត្រីពាក់ព័ន្ធនឹងការបាញ់ប្រហារ» ឌឹ ភ្នំពេញ ប៉ុស្ដិ៍ (ថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៤) http://bit.ly/1cyH93f.

តាមលោកឧត្តមសេនីយ៍ត្រី ខេង ទីតូ ពុំមានការចោទប្រកាន់ណាបានធ្វើឡើងចំពោះមន្ត្រីទាំង ៥នាក់ នោះឡើយ ដោយហេតុថាអ្វីដែលពួកគេធ្វើគឺជាការការពារខ្លួនស្របច្បាប់តែប៉ុណ្ណោះ។ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានលើកសរសើរចំពោះកងកម្លាំងរក្សាសន្តិសុខដែលខិតខំការពារសណ្តាប់ធ្នាប់សង្គម និងសន្តិសុខ។[14] រដ្ឋាភិបាលបានលើកសរសើរចំពោះសកម្មភាពរបស់កងកម្លាំងរក្សាសន្តិសុខ ជាជាងពិនិត្យមើលលើការប្រើអំពើហិង្សាដែលបណ្តាលឲ្យមនុស្ស ៦ នាក់ ស្លាប់ និងមួយចំនួនរងរបួស និងមានម្នាក់បានបាត់ខ្លួន។ រដ្ឋាភិបាល ពុំបានយកចិត្តទុកដាក់ការពារលើសិទ្ធិរបស់ជនរងគ្រោះ និងក្រុមគ្រួសារក្នុងការទទួលបានការពិត យុត្តិធម៌ និងដំណោះស្រាយតាមផ្លូវច្បាប់នោះទេ។ លោកអ្នកអាចស្វែងរកព័ត៌មានបន្ថែមពាក់ព័ន្ធទៅនឹងអំពើហិង្សាប្រព្រឹត្តដោយកងកម្លាំងរក្សាសន្តិសុខក្នុងយុទ្ធនាការមួយរបស់ ម.ស.ម.ក ស្តីពី "ឯណាយុត្តិធម៌ខ្ញុំ" ។

## និទណ្ឌភាព និងវប្បធម៌នៃភាពភ័យខ្លាច

ស្របនឹងការប្រើប្រាស់អំពើហិង្សាទៅលើក្រុមអ្នកតវ៉ា និទណ្ឌភាព ត្រូវបានប្រើប្រាស់ដើម្បីបង្កើតឲ្យមានវប្បធម៌នៃភាពភ័យខ្លាច និងរារាំងប្រជាពលរដ្ឋក្នុងការស្វែងរកការពិតនៅកម្ពុជា។ បញ្ហាទាំងនេះបានបង្ហាញឲ្យឃើញយ៉ាងច្បាស់ ពេលដែលករណីឃាតកម្មលើអ្នកការពារសិទ្ធិមនុស្ស និងអ្នកសារព័ត៌មាន ដែលមិនមានការស៊ើបអង្កេតច្បាស់លាស់។ ក្នុងឆ្នាំ២០០៤ លោក ជា វិជ្ជា មេដឹកនាំសហជីពត្រូវឃាតករបាញ់សម្លាប់ទាំងកណ្តាលថ្ងៃត្រង់ នៅក្នុងទីក្រុងភ្នំពេញ។[15] ក្នុងឆ្នាំ២០១២ លោក ហង្ស សេរីឧត្តម អ្នកសារព័ត៌មានដែលរាយការណ៍ពីករណីកាប់ព្រៃឈើខុសច្បាប់ ត្រូវគេរកឃើញថាបានស្លាប់នៅក្នុងគូថឡានរបស់លោកដោយមានស្នាមរបួសកាប់នឹងពូថៅ។[16] ក្នុងឆ្នាំ២០១៣ លោក ឈុត វុទ្ធី សកម្មជនការពារបរិស្ថាន ត្រូវបានបាញ់សម្លាប់បន្ទាប់ពីមានជម្លោះជាមួយមន្ត្រីយោធាក្នុងខេត្តកោះកុង។ [17] ករណីឃាតកម្មទាំងនេះមិនត្រូវបានស៊ើបអង្កេតឲ្យបានដិតដល់ ឬករណីខ្លះត្រូវទម្លាក់ការចោទប្រកាន់, ករណីនេះគឺតំណាងឲ្យជនរងគ្រោះដទៃទៀតដែលទទួលបានលទ្ធផលប្រហាក់ប្រហែលគ្នាដោយសារតែការស្វែងរកការពិត។ ឧទាហរណ៍ ចាប់តាំងពីឆ្នាំ ១៩៩៤ មក មានអ្នកសារព័ត៌មាន ចំនួន ១៣ នាក់ ត្រូវបានសម្លាប់ ហើយករណីរបស់ពួកគេនៅតែស្ថិតក្នុងស្ថានភាពនិទណ្ឌភាពនៅឡើយ។[18]

ចុងក្រោយ អាជ្ញាធរដែលមានអំណាច ឬបុគ្គលដែលមានទំនាក់ទំនងល្អជាមួយអ្នកកាន់អំណាចតែងតែរួចពីការផ្តន្ទាទោស។ ឧទាហរណ៍ នៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១២ កម្មការិនីរោងចក្រ ៣នាក់ ដែលបានតវ៉ានៅខាងក្រៅរោងចក្រ កៅវេយ៍ ស្ពត អិលធីឌី នៅខេត្តស្វាយរៀង ត្រូវ លោក ឈូក បណ្ឌិត អតីតអភិបាលក្រុង

---

[14] ឃួន ណារីម និង ខូលីន ម៉េយ «មិនមានលទ្ធផលចំពោះការស៊ើបអង្កេតលើការបាញ់ប្រហារ» ឌឹ ខេមបូឌា ដេលី (ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៤) http://bit.ly/1dWztbk.
[15] ដេនីស ហ៊ើប៊ី «ការសម្លាប់មេដឹកនាំសហជីព ជា វិជ្ជា មួយទសវត្សរ៍កន្លងទៅ» ឌឹ ខេមបូឌា ដេលី (ថ្ងៃទី២២ ខែមករា ឆ្នាំ២០១៤) http://bit.ly/1jAqVe5
[16] រដ្ឋា វិសាល «តុលាការកម្ពុជាលើកលែងការចោទប្រកាន់ចំពោះ ជនសង្ស័យពីរនាក់ ពាក់ព័ន្ធនឹងការសម្លាប់អ្នកសារព័ត៌មាន» វិទ្យុអាស៊ីសេរី (ថ្ងៃទី២៨ ខែសីហា ឆ្នាំ ២០១៣) http://bit.ly/1pV7Y6I
[17] ក្លូធីល ឡឺ កូស «ការស្លាប់របស់ លោក ឈុត វុទ្ធី រួមចំណែកតិចតួចក្នុងការលុបបំបាត់ការកាប់ព្រៃឈើខុសច្បាប់នៅកម្ពុជា» អាស៊ាន កូរ៉េស្បុង់ឌិន (ថ្ងៃទី២៩ ខែមេសា ឆ្នាំ ២០១៣) http://bit.ly/1BwAN1V
[18] អ្នកសារព័ត៌មានដែលត្រូវបានសម្លាប់ (*Sithi.org*) http://bit.ly/1tENYZS.

បារិតបាញ់ឲ្យរបួស។[19] ការឆ្លើយបំភ្លឺដំហានដំបូងរបស់លោក ឈូក បណ្ឌិត សមស្របទៅនឹងចម្លើយសាក្សី ប៉ុន្តែចម្លើយនេះត្រូវបានលុបចោលវិញនាពេលក្រោយ ដែលរៀបរាប់ថាបានឃើញថាលោក ឈូក បណ្ឌិត បាញ់ទៅលើក្រុមអ្នកតវ៉ា។ ខណៈដែល លោក ឈូក បណ្ឌិត ត្រូវបានរកឃើញថាបានប្រព្រឹត្តបទល្មើសបង្ករបួសស្នាមដោយអចេតនា ការចោទប្រកាន់នេះមិនសមស្របទៅនឹងទង្វើដែលគាត់ប្រព្រឹត្តឡើយ មិនតែប៉ុណ្ណោះ លោក ឈូក បណ្ឌិត នៅតែមានសេរីភាពជាធម្មតា។

ការខកខានក្នុងការចាត់វិធានការស៊ើបអង្កេត និងចោទប្រកាន់ទៅលើករណីទាំងនេះ បានបង្ហាញថា បុគ្គលមួយចំនួនមានអំណាចលើប្រព័ន្ធតុលាការកម្ពុជា និងបង្ហាញឲ្យឃើញពីវប្បធម៌និទណ្ឌភាពដែលមានវត្តមាននៅកម្ពុជា ដែលទាំងអស់នេះបង្កឲ្យមានភាពភ័យខ្លាចក្នុងការនិយាយការពិត។ លោកអ្នកអាចស្វែងរកព័ត៌មានបន្ថែមស្តីពីនិទណ្ឌភាព និងផលប៉ះពាល់ ក្នុងយុទ្ធនាការនិទណ្ឌភាពឆ្នាំ ២០១៣ របស់ ម.ស.ម.ក ។

## សេចក្តីសន្និដ្ឋាន

កង្វះឆន្ទៈរបស់រដ្ឋាភិបាលក្នុងការលុបបំបាត់និទណ្ឌភាព បានបង្ហាញថារដ្ឋាភិបាលអនុញ្ញាតឲ្យការរំលោភបំពានសិទ្ធិមនុស្សធ្ងន់ធ្ងរ ដូចករណីខាងលើបានបង្ហាញស្រាប់ នៅតែបន្តកើតមាន។ ការស្វែងរកយុត្តិធម៌មិនមែនសំខាន់សម្រាប់តែជនរងគ្រោះ និងក្រុមគ្រួសារនោះទេ តែក៏មានសារៈសំខាន់ចំពោះសេរីភាពបញ្ចេញមតិនៅកម្ពុជាផងដែរ។

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាអំពាវនាវដល់រដ្ឋាភិបាលឲ្យ៖

- ចាត់វិធានការស៊ើបអង្កេតឲ្យបានម៉ត់ចត់ ឯករាជ្យ និងប្រកបដោយប្រសិទ្ធភាពទៅលើករណីរំលោភសិទ្ធិមនុស្ស និងអំពើឃាតកម្មមកលើអ្នកការពារសិទ្ធិមនុស្ស ព្រមទាំងអ្នកសារព័ត៌មាន
- បញ្ចេញជាសាធារណៈនូវរាល់ព័ត៌មានដែលបានមកពីការស៊ើបអង្កេត
- នាំខ្លួនជនល្មើសដែលប្រព្រឹត្តអំពើរំលោភសិទ្ធិមនុស្សទាំងនោះទៅផ្តន្ទាទោសតាមច្បាប់
- គាំពារសិទ្ធិជនរងគ្រោះក្នុងការស្វែងរកយុត្តិធម៌ ការពិត ព្រមទាំងការទាមទារសំណងផ្សេងៗ

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង កញ្ញា សន រ៉ាមណា អ្នកសម្របសម្រួលគម្រោងសេរីភាព បញ្ចេញមតិតាមរយៈទូរសព្ទ +(855) 17 655 591 ឬ ramanasorn@cchrcambodia.org ។**

[19] ម.ស.ម.ក «ឈូក បណ្ឌិត» (សលាកប័ត្រព័ត៌មាន) (ខែវិច្ឆិកា ឆ្នាំ២០១៣) http://bit.ly/1w3IjOt.